# ប្អូនស្រីទុរយស

«អ្នកនាងពិនណា គ្នាយើងឱ្យដំណឹងមកថា លោកប្រុស Lorenzoទុកឡានចោលនៅហាងកាហ្វេ starbukcs ហើយ ឡើងទៅជិះជាមួយអតីតប្រធាននិស្សិតឈុនរាជចេញក្រៅក្រុង!»

នារីមានល្បិចឈប់ផ្ទឹង ក្រោយពេលដែលទទួលបានដំណឹងចុងក្រោយនេះ។ ទឹកមុខនាងខូចចិត្តតែមិនមែនកម្សត់ទេ ព្រោះកាន់តែមើលកាន់តែភ័យខ្លាចទៅវិញ។ នាងហាក់សោកស្តាយស្រណោះនូវអ្វីម្យ៉ាងជាជាងកើតទុក្ខស្នេហ៍។

សំឡេងជំនួយការថ្មី ដែលនាងដាក់នៅក្បែរខ្លួនLorenzoចាប់រៀបរាប់បន្ថែម៖

«តាមព័ត៌មានផ្សេងៗដែលគ្នាយើងពង្រាយលបស្តាប់ពួកគេ យើងអាចសន្និដ្ឋានបានថា ពួកគេចេញទៅផ្ទះអនាគត!»

នារីអភិជនចាកចោលម៉ាស៊ីនហាត់សម្រករាង។ នាងបែរមកក្រោយហើយសម្លឹងអ្នករាយការណ៍ជាមួយវាចាមួយៗ៖

«ខ្ញុំទាយដឹង តាំងពីពេលដែលនាងហ្នឹងបានចូលជួបLoren! ជាកំហុសពីណាគេ? ខំទុកឱ្យនៅជាមួយLoren ធ្វើជាទ្វារ ជារបង! បំបង់បាយដែលគ្រាន់តែ រាំងរាំង២នាក់ហ្នឹងប៉ុណ្ណឹងក៏ធ្វើមិនបានសមថា យកប្រាក់ខែទៀតដែរអត់?»

ជំនួយការបង្កប់ខ្លួនឈ្ងោកមុខទទួលខុស ។

«ពិនណា ! បើគេដឹងរឿងពិតហើយ មិនព្រមរៀបការក៏តាមហ្នឹងទៅក្អួយ!»

ពិនណាសម្លឹងបុរសដែលទើបនឹងដើរចូលមកដល់។ ឃើញមុខគេភ្លាម នាងរឹតតែក្តៅក្រហាយក្នុងចិត្ត ។ ស្រីស្អាតលែងនិយាយស្តី ដែលូកទាញកន្សែង ជូតញើសចេញដើរចោលបុរសទាំងទ្វេ តម្រង់ទៅ ជាន់ខាងលើ។

ដើរផងចិត្តហេងហាងដូចមនុស្សហៀបត្រូវឆ្នោតរង្វាន់ធំបែរជាមិនអាចបើកយកលុយបាន ។

«ឯងនៅតាមចងពៀរយើងដល់ណាទៀតនាងល្អអើយ!»

រូបរាងសន្យា អណ្តែតមកក្នុងកែវភ្នែកធីតាអភិជន។ គិតយ៉ាងណា ក៏នាងនៅតែមិនទុកចិត្តថា Lorenzoមិនវិលទៅស្រលាញ់ងប់លើអតីតគូស្នេហ៍វិញនោះដែរ។

មនុស្សសាងអាក្រក់ និងស្នេហាដែលមិនចេញពីបរិសុទ្ធចិត្ត រមែងបង្កើតជាទុក្ខទោសៈដល់អ្នកណាដែលកំពុងឱបក្រសោបវា។ តួយ៉ាងពេលនេះ ជិតក្លាយជាកូនក្រមុំរបស់គេទៅហើយ ហេតុអ្វី ស្រីស្អាតនៅមិនសុខមិនសាប់បើគ្រាន់តែ គេនោះចេញទៅក្រៅក្រុងសោះ?

«បើវាមិនមែនជាស្នេហា វានឹងនាំរឿងអន្តរាយដល់ជីវិតក្មួយ!»

សំឡេងបុរសចំណាស់នៅតែតាមមកពីក្រោយ ធ្វើឱ្យធីតាដែលមិនចង់ប្រឈមនឹងគាត់ ងាកមុខចេញ ទាំងខាំមាត់ខឹង។

សម្រឹបជើងម្ចាស់សម្តីឡើងមកទីបៗពីក្រោយខ្នង ធ្វើឱ្យនាងមិនត្រឹមតែ មិនតបតអ្វីគឺពិនណា រុញទ្វារបន្ទប់មួយក្បែរនោះចូលតែម្តងជាការប្រាប់ថានាងមិនចង់និយាយអ្វីនឹងគាត់ទាំងអស់។

ទោះយ៉ាងណា គាត់នៅតែតាមមក។

បុរសចំណាស់រវេក្មេក សម្លឹងបរិវេណបន្ទប់។

ទីនេះជាកន្លែងដែលនាងនិងគាត់ខ្លួនឯងមិនសូវឡើងមកទេ លើកលែងតែពេលបុណ្យទានចាំបាច់បង្គ្រប់កិច្ច។

ផ្សែងធូបចោលក្លិនមក ទើបពិនណាចាប់អារម្មណ៍ថា នេះជាថ្ងៃសីល។ សន្យាតែងតែអុចធូប នៅនឹងមុខអាសនៈដែលមានតាំងរូបថតបុរសចំណាស់នេះ។ អ្នកដែលខ្លួននាងតែងហៅថាប៉ា តាំងពីតូចមក ហើយក៏ជាអ្នកដែល សន្យាទើបនឹងបានជួបវិញក្រោយការនិរាសម្ភៃឆ្នាំ។

ពិនណាបែរខ្នាច់មកនិយាយជាមួយរូបថតទាំងរលីងរលោង៖

«ប៉ា! មង្គលការដំបូងរបស់ផ្ទះនេះ មិនអាចរំសាយបានទេ! បើប៉ាសក្តិសិទ្ធិមែន ប៉ាទៅនាំចិត្តនាងនោះឱ្យទៅរស់នៅស្រុកព្រៃតាមរបៀបវាវិញទៅ កុំឱ្យកូនក្រៅខោររបស់ប៉ា ធ្វើរឿងរញ៉េរញ៉ៃពេញផ្ទះនេះ! !»

«ឈប់ធ្វើអ៊ីចឹងទៀតពិនណា?»

បុរសចំណាស់ហាមឃាត់ធ្វើឱ្យនាងដែលខំអត់មិននិយាយរកគាត់យូរមកហើយបែរមកបញ្ចេញកំហឹងទាំងស្រុងលើបុរសនេះវិញ៖

«អ្នកណាឱ្យពូនិយាយ? ពូអាងអីមកលូកមាត់លូកកថាស្តីប្រដៅខ្ញុំ! អ្ហូ បែបពូគិតថា ដែលមុនប៉ាស្លាប់ ប៉ា ប្រាប់ឱ្យខ្ញុំទទួលស្គាល់ពូជាឪពុកហ្នឹង ពូក៏អាចក្លាយជាអ្នកត្រួតជីវិតខ្ញុំបាន!ពូទំនេរមើល

ខ្លួនឯងក្នុងកញ្ចក់ម្តងទៀតទៅ! ខ្ញុំជាកូនស្រីតែម្នាក់គត់របស់នាយកគ្រឹះស្ថានOC ទោះមានអ្នកណាមកអះអាងអ្វីក៏ខ្ញុំមិនទទួលស្គាល់មនុស្សដូចពូជាឪពុកដែរ ទោះបីជាអតីតកាលពូបែបណា វាជារឿងរបស់អ្នកទាំងពីរតែខ្ញុំគ្មានថ្ងៃទទួលយកអតីតកាលដ៏គម្រក់ហ្នឹងទេ!ពូចាំទុក!»

បុរសចំណាស់ឈ្ងោកមុខទាំងខ្មៅប៉ៃ។ វិបត្តិជីវិតដែលលបលួចយកកូនខ្លួន មកប្តូរជាមួយកូនបងប្រុសដើម្បីលាភសក្ការៈ  មិនត្រឹមមិនអាចជួសសងនូវកំហុសនៅមុខវិញ្ញាណបងប្រុសធំបាន ថែមទាំង មានកូនស្រីអកតញ្ញូ ដែលមិនព្រមទទួលយកសូម្បីតែការពិតរបស់ខ្លួនឯងហើយកំពុងបង្កើតនូវរឿងស្នេហ៍បែបនរកជំនាន់ថ្មីបន្ថែមលើរឿងអាស្រូវចាស់។

«ឯងទទួលស្គាល់មិនទទួលស្គាល់ពូជាប៉ា!  ពូគ្មានអ្វីនិយាយទេពិនណា! តែពូមិនចង់ឱ្យជីវិតក្មួយដើរតាមគន្លងមុន គឺសាងរឿងស្នេហាមិនត្រង់ ដែលនាំមកនូវវិប្បដិសារីពេញមួយជីវិត!»

ពិនណាក្រពាត់ដៃ ចចេសនិយាយទាំងមិនព្រម សម្លឹងមុខបុរសម្ចាស់កំណើតខ្លួនម្នាក់នេះដាច់ខាតៈ

«ដែលខ្ញុំមានវិប្បដិសារីជាងគេ គឺព្រមស្តាប់សម្តីរបស់ពូ ឱ្យវាមកនៅសុខសប្បាយលើផ្ទះនេះ!»

បុរសដើរមួយៗមករកកូនស្រី ហើយគាត់ចាប់ស្មានាងថ្នមជាមួយពាក្យលួងៈ

«ពិនណា ពីតូចមកពូទុកឯងដូចជីវិតពូ! ពូហ៊ានទាំងលើកដៃពបីក្មួយបង្កើតយកទៅបំបរបង់ចោលនៅចុងកាត់មាត់ញក ក៏ព្រោះតែចង់ឱ្យឯងបានងារជាអ្នកនាងធំ គ្មានគូប្រជែង! មិនបានប៉ុន្មានម៉ាក់ឯងធ្លាក់ខ្លួនឈឺមើលមិនជាសោះ! នេះជាកម្មពៀរដែលពិតជាមានក្នុងវាលវដ្តសង្សារនេះ! ពូមិនចង់ឱ្យគ្រប់គ្នា មានរឿងដូចពីមុនទៀតទេ! បណ្តោយតាមព្រហ្មលិខិតចុះណ៎ាបើប្រុសម្នាក់នោះ រើសយកបងស្រីឯងគឺ វាជារឿងបុព្វេ ដែលមិនអាចប្រឆាំងបាន!»

ពិនណាតាមពិតត្រូវការការលួងលោម ក្នុងកាលៈទេសៈនេះ បានជានាងបង្អង់ព្រមស្តាប់និងព្រមឱ្យឪពុកគ្មានខាន់ស្លាម្នាក់នេះអង្អែលស្មា ដឹងអីគាត់បែរជាសូត្រទ្រឹស្តីបុណ្យបាបក្នុងពេលដែលនាងពិតជាត្រូវការកម្លាំងជំនួយ។ នារីនេះ កើនអារម្មណ៍ដ៏កោលាហល។ ពិនណា ញោចប្រាណច្រានដៃឪពុកធ្លាក់ចេញ ហើយងាកមកបម្រុងដំឡើងសំឡេងដាក់គាត់ ស្រាប់តែភ្នែកនាងវាត់ ទៅ វាក់អើនឹងអ្នកណាម្នាក់បង្ហាញខ្លួនក្រោយទ្វារ.....

ប្រតិកម្មនាងក៏បង្ខំឱ្យបុរសចំណាស់ងាកទៅរកទិសដៅនោះភ្លាមដែរ.....

សន្យាបង្ហាញខ្លួនសន្សឹមៗនៅចំពោះកែវភ្នែកឪពុកកូននេះ ជាមួយទឹកមុខឈឺចាប់។

នាងរលើងរលោង ចេញមកពីក្រោយទ្វារ ហើយនាងប្រឹងទប់ស្កាត់ចិត្តពុះកញ្ជ្រោលនិយាយអួលៗទៅកាន់ពួកគេ។

«ខ្ញុំស្មានតែពាក្យអេចអូចទាំងអស់នោះ គ្រាន់តែជារឿងចចាមអារ៉ាម មិនស្មានថា វាជាការពិត ដែលក្មួយស្រីម្នាក់ ត្រូវបាន យកទៅបោះចោលអស់ម្តៃឆ្នាំដោយដៃលោកមាខ្លួនឯង ហើយបងប្រុសម្នាក់ត្រូវក្អួតឈាមស្លាប់ព្រោះដឹងរឿងអប្រិយអស់ទាំងនេះ! ចុងក្រោយអ្នកទាំងពីរនៅតែមានល្បិចមិនឈប់ក្នុងការបោកប្រាស់ជីវិត Lorenទៀត?ធ្វើអញ្ចឹងធ្វើអី?»

ពិនណាដែលកំពុងរន្ធត់ព្រោះតែដឹងថា មានគេមកស្តាប់ដឹងប្រវត្តិរបស់នាង ពេលឮថាសន្យាមិនត្រឹមដឹងថែមទាំងយល់ជ្រៅ អស់សេចក្តីទៀត នាងកាន់តែតក្កមា ។

«ឯងនិយាយស្អីនាងល្អ?អ្នកណាបោកអ្នកណាអ្ហះ?!»

សន្យាបូញមាត់ឈឺចាប់។

ព្រោះតែនាងទើបនឹងស្តាប់ឮការពិតទាំងនេះចេញពីមាត់ប្អូនស្រីដែលជាសាច់ឈាមរួម ដោយមានឪពុកក៏ជាបងប្អូនបង្កើត ក៏ប៉ុន្តែ ពិនណា បែរជាមាន ចរិតមហាសែនខុសគ្នា មេឃហើយនិងដី ចុងក្រោយនេះថែមទាំងទទូចចង់រៀបការជាមួយមនុស្សប្រុសមិនស្គាល់ខ្លួនឯងម្នាក់ទាំងដឹងហើយថាបងស្រីខ្លួនទើបជាមនុស្សដែលគេស្រលាញ់។

នាងនិយាយមួយៗទាំងឈឺចិត្តៈ

«ពិនណា! គ្រប់យ៉ាងលើលោកនេះ តែងតែចប់ទៅជាមួយការពិត! កាលដែលឯងបានកុហក Lorenzoពីអតីតកាលរបស់គេ ហើយព្យាយាមបង្ខំខ្លួនឯងឱ្យរស់ជាមួយការកុហកសូម្បីតែខ្លួនឯងនេះ គឺវាមិនបានសម្រេចទេ! ការពិតវាបានលេចចេញមកហើយ !បើបងធម៌ខ្ញុំនាំគេទៅដល់កន្លែងនោះមែន គេនឹងដឹងការពិតគេនឹងចងចាំ»

ដែលពិនណារឹតតែសៅហ្មង គឺ នាងជិតរៀបការហើយបែរកំពុងព្រួយ ចំណែកស្រីម្នាក់ទៀត មិនទាំងបានគេនឹកឃើញស្គាល់ផង បែរជាមានជំនឿចិត្តខ្ពស់ថ្នាក់នេះ?

ទាំងច្រណែនទាំងប្រចណ្ឌទាំងទោមនស្សស្តាយយសសក្តិ អំណាចនិងបុរសអ្នកមានដែលហៀបធ្លាក់ដល់ដៃ ពិនណាទៅជាប្តូរទឹកមុខបង្កើតឆាកញញឹមហើយឌឺដងបញ្ចោះបន្សេ្យាកគូសន្ទនា ៖

«ពូកែសូត្រទ្រឹស្ដីណាស់សូត្រទៀតទៅនាង! សូត្រចប់កាលណា ចាំបើកភ្នែកធំៗមើលលទ្ធផលចុងក្រោយទៅ! យើងរវល់! មិនមានពេលកំដរឈ្លោះទេ! ប្រញាប់ទៅលរ៉ូប និងសាកទ្រង់គ្រឿង ត្រៀមសម្រាប់អាពាហ៍ពិពាហ៍របស់យើង!»

នាងប្រុងបែរចេញទៅដោយឈប់និយាយ ដឹងអីចិត្តមួយនៅតែកម្រើកបិសាច មិនស្កប់ក្នុងការធ្វើឱ្យសន្យាឈឺចាប់សោះ បានជាពិនណា ឈប់ជើងមកវិញហើយបន្ថែមឃ្លាបង្អើយ៖

«គឺរៀបការជាមួយសុភាពបុរសគ្មានអតីតកាលម្នាក់! តែគេ មានទ្រព្យសម្បត្តិមហាសាល! ថែមទាំងមានចរិតល្អចំពោះយើង គ្មានស្រីណាមានវាសនាដូច!»

ពិនណាចាកចេញទៅ ប៉ុន្តែសម្ដីនាងចុងក្រោយ ព្រមទាំងកាលដែល សន្យា រវៃភ្នែកទៅសម្លឹងប៉ះចិញ្ចៀនភ្ជាប់ពាក្យលើម្រាមនាងដៃនៃប្អូនស្រីជួជាតិ កាលណា ម្ចាស់ផ្ទះអនាគត ផ្ទុះកើតចិត្តតឹងថប់ពេញទ្រូងដោយក្ដីសៅហ្មងនិងមិនសុខចិត្ត ។

សន្យា ដើរលឿនស្ទេរតាមពីក្រោយ ហើយនិយាយរ៉ាវ៖

«ឯងរៀបការនឹងគេតែមិនបានស្រលាញ់គេទេ មែនអត់ពិនណា!? ឯងយករឿងរៀបការមកលេងសើច ឯងដឹងថាវាបំផ្លាញទាំងអស់គ្នាអត់ពិនណា?»

ពិនណាខាំមាត់បែរមកវិញភ្លែតជាមួយសម្ដីតវ៉ា៖

«ទោះយ៉ាងណា យើងនឹងក្លាយជាកូនក្រមុំរបស់គេជៀសមិនរួចទេបងស្រីសំណព្វ! ឯងរស់ចាំមើលឈុតឆាកល្អៗនៃជីវិតយើង ហើយត្រៀមខូចចិត្តតទៅទៀត តាមរបៀបមនុស្សច្រណែនគេឡើងខូចសតិទៅចុះសន្យា! គ្រប់យ៉ាងមិនអាចទៅរួចសម្រាប់មនុស្សច្រឡំកំណើតដូចឯង! កុំថាឡើយកំណើតឯងជាអ្នកមាន ! សូម្បីតែមានបុណ្យតិចតួចបានជួបគេហើយ ក៏នៅតែទេវតាបណ្ដាលឱ្យគេភ្លេចឯងបាន ? ឯងប្រឹងជួបគេប៉ុន្មានលើកទៀត! មនុស្សដែលភ្លេចឯងហើយគេនឹងភ្លេចឯងជារៀងរហូត! Lorenzoគ្មានថ្ងៃដូចដើមមកដឹងរឿងអតីតកាលរបស់គេនោះទេ! ឯងឈប់ត្រដរចាំទៅ!»

ស្នាមញញឹមកោងកាចនៃមនុស្សស្រីវ័យក្មេងម្នាក់នេះ បានធ្វើឱ្យសន្យានឹកឃើញដល់តម្រុយជាច្រើន។ ការពិតច្បាស់ដូចថ្ងៃចំពោះមុខហើយសង្ស័យអីទៀត? ពិនណាមានចេតនាមិនឱ្យLorenzoដឹងអ្វីគ្រប់យ៉ាងដែលគេគួរដឹង។ មិនត្រឹមតែប៉ុណ្ណឹង ស្រីចិត្តបិសាចម្នាក់នេះក៏ប្រហែលជានៅពីក្រោយហេតុផលដែលកន្លងមកអតីតម្ចាស់ចិត្តមិនព្រមមកជួបខ្លួនសោះនោះផង។

នាងនិយាយដោយខាំមាត់សង្កត់ចិត្ត៖

«បើឯងមិនមែនមានឈាមជាមួយយើង យើងនឹងចាត់ការគំនិតស្មោកគ្រោករបស់ឯងហើយពិនណា! ឥឡូវ ទាន់នៅមានពេលបកក្រោយនៅឡើយ ! យល់ដល់ប៉ា យើងឱ្យឯងឆាប់ទៅផ្តាច់ពាក្យហើយ ចែកផ្លូវទៅរកអនាគតពិតប្រាកដរបស់ឯងទៅ កុំយកមង្គលការមកធ្វើជារឿងលេងសើច បើឯងចង់បានទ្រព្យសម្បត្តិទាំងអស់នៅOCយើងស៊ីញ៉េឱ្យ!»

ពិនណានៅធ្មឹងសញ្ជឹងគិត។

ហេតុអ្វីមានមនុស្សស្រីដែលសុខចិត្តចោលមរតកច្រើនយ៉ាងនេះដើម្បីដូរជាមួយមនុស្សគ្មានអតីតកាលម្នាក់? ឬមួយក៏Lorenzoមានអ្វីសម្បើម លើសពីអ្វីដែលនាងកំពុងដឹង? នេះជាគំនិតពិចារណាតាមបែបមហិច្ឆតាគ្មានថ្ងៃឈប់របស់  ពិនណា។ ចុងក្រោយអ្វីមួយដែលនាងនឹកឃើញ គឺថា ទោះមានអ្វីកើតឡើងក៏ដោយ នាងត្រូវតែបានLorenzo។

ស្រីស្អាតចិត្តខ្មៅបែរមកវិញហើយទម្លាក់សំឡេងនិយាយមួយៗមកកាន់កែវភ្នែកមូលក្រឡង់របស់បងស្រី ។

«ឯងស្តាប់ឱ្យទាន់នាងតួចិត្តល្អ! ការលះបង់របស់ឯង វាគ្មានអ្វីអាចមកធ្វើឱ្យមនុស្សដូចខ្ញុំរំភើបហើយទៅលើកទង់ជ័យសចាញ់បោកឯងព្រោះសម្តីមនោគមប៉ុន្មានម៉ាត់ហ្នឹងទេ! ឯងពូកែនិយាយតែយើងក៏មិនឆោត! ចាំទុក! ល្បែងមួយក្តារនេះយើងលេងក្បែរឈ្នះទៅហើយ នៅសុខៗឯងចង់ឱ្យយើងឆាចោល? ប្រសិនឯងមានៈហ៊ានធ្វើឱ្យLorenងាកទៅរកវះកាត់! ឯងនឹងស្តាយក្រោយ!»

សន្យាលើកចិញ្ចើមទាំងងឿងឆ្ងល់ជាមួយពាក្យភ្លាត់ឆ្លោយសួរតិចៗ៖

«វះកាត់?!»

ពិនណាញាក់ចិញ្ចើមញញឹមហើយនិយាយពន្យល់មួយៗទាំងបានចិត្ត៖

«លទ្ធផលនៃការវះកាត់មានតែពីរប៉ុណ្ណោះ គឺចាំរឿងរ៉ាវបានមកវិញឬមួយក៏ដេករហូត! ព្រោះតែការចង់ឈ្នះ  ឯងយកជីវិតគេទៅប្តូរបានន័យថាឯងមានស្នេហាស្មោះ?»

សន្យាស្រឡាំងកាំងចំពោះព័ត៌មាននេះ។ នាងភ័យណាស់តែនាងគ្រវីក្បាលបដិសេធក្នុងការទទួលយក ។

បានដូចចិត្ត ពេលឃើញគូបដិបក្ខចូលស៊ង នារីអភិជនចិត្តជាមារ រួសរាន់ដើរមកក្បែរបងស្រីហើយបន្តវាចាបន្ថែមដាក់ត្រចៀកនាង ៖

«ឯងចំណាប់ណាស់ ប្រើមហាមាយារបស់ឯងឱ្យគេទន់ចិត្ត ហើយចង់ទៅសើរើរឿងចាស់ជាមួយឯង! ឯងខ្លាំងដល់ថ្នាក់ហ៊ានថើបមនុស្សប្រុសដែលគេមិនព្រមទទួលស្គាល់ឯង! ឯងសាហាវអញ្ចឹង ឯងមានដឹងអត់ថា បើបងប្រុសរបស់ឯង លោតែនាំស្លុយនាំគេទៅដល់កន្លែងនោះ ហើយគេរកឃើញអ្វីសង្ស័យ គេក៏ដាច់ចិត្តឡើងគ្រែវះកាត់ លទ្ធផលចុងក្រោយឯងទទួលយកបានដែរ? ស្រីអាត្មានិយម!»

សន្យារលើងរលោង នាងលែងចង់ស្តាប់ហើយនាងរឹតតែមិនចង់ស្រមៃទេពេលដែលគេក្លាយជាមនុស្សពិការអស់មួយជីវិតដោយសាររឿងនេះ។

**បាច់ផ្កាស្រពោន និងកំណត់ហេតុចាស់**

ឡានរបស់ ឈុនរាជឈប់ង៉ក់ពីមុខកូនផ្ទះតូច។

«ច្រើនឆ្នាំហើយដែល អ្នកខ្លះធ្លាប់របួសមកដេកព្យាបាលកណ្ដាលព្រៃនេះ ពីរនាក់ប្អូនស្រីខ្ញុំ!  កាលណោះ ផ្ទះនេះតូចទាបកំប៉ិត! ប៉ុន្មានឆ្នាំមកនេះ ថ្ងៃទំនេរណាមួយ ក៏វាបើកឡានមកអង្គុយសំកុក ហើយរៀបចំ ផ្ទះ លើកផ្ទះ ដាំផ្កា ធ្វើដូចមានអ្នកណាម្នាក់ ជិតត្រឡប់មករកវាវិញ! វាមិនដឹងទេថា មនុស្សខ្លះ ពេលឃើផ្សេង ពេលជាផ្សេង!»

សម្តីចាក់ដោតរបស់ឈុនរាជមិនត្រឹមតែមិនបាន ធ្វើឱ្យ Lorenzoខឹងសម្បារអ្វីប៉ុនកម្ទេចល្អង គេថែមទាំងស្លុងទៅក្នុងការពណ៌នានិងទឹកមុខស្រងូតរបស់នាងដែលផ្ចិតច្បាស់ ក្នុងការចងចាំរបស់នាយ។

«នាងថើបយើង ទាំងដែលយើងលែងស្អាតសង្ហា នាងមិនបានប្តូរទេ!មិនថាការរៀបរាប់របស់និស្សិតនេះជារឿងប្រឌិតឬប្រលោមលោក វាពីរោះពេកហើយ! យើងក៏ចង់ឱ្យខ្លួនឯងជាតួប្រុសក្នុងសៀវភៅកុហករបស់នាងដូចគ្នា!»

គេគិតផង ដៃទាំងទ្វេជ្រែងហោប៉ៅលុបចិត្តលន្លង់លន្លោច ហើយដើរមួយៗចូលតាមទ្វារឈើក្រោមការរុញនាំផ្លូវរបស់បុរសកន្តុល។

សំឡេងនាយឈុនរាជលាន់មកបន្ថែមៈ

« មនុស្សក្បត់ចិត្តដូចឯង តាមថាមិនសមទទួលស្វាគមន៍ឱ្យចូលផ្ទះនេះម្តងទៀតសោះរ៉ី!»

Lorenzoគ្មានពេលមកស្តាប់ការរអ៊ូនេះឡើយ។ ភ្នែកគេផ្តោតលើសំណុំបាច់ផ្កាដែលក្រៀមស្រពោនហើយលំអរទុកហាក់សំខាន់ខ្លាំង នៅចំកណ្តាលផ្ទះ ក្នុងលើថូថ្លើមឈើខ្មៅរលោង។

ចូនេះ តាំងលំអរលើកូនឫស្សីពណ៌ក្រហមក្រមៅ។

អ្នកណាជូនផ្កានេះដល់នាង បានជាវាអាចក្លាយជាសំណព្វចិត្តនាងបានអ្ហះ សន្យា?

គេគិតតែមិនស្រដីសូម្បីកន្លះម៉ាត់ណា។

ឈុនរាជចេញទៅវិញហើយ។

មិនដឹងគេមិនចង់និយាយរកនាយពិតមែន ឬមានបំណងទុកពេលនេះសម្រាប់នរៈយើងពិចារណាកំហុស?

គេលូកដៃទៅទាញស្រោមសំបុត្រមួយតូចសៀតជាប់លើបាច់បុប្ផាក្រៀមស្វិត។

វាជាលិខិត ស្នេហា ដែលសរសេរលើក្រដាសពណ៌ជម្ពូរ ហើយមានត្រឹមមួយឃ្លាគត់ថា។

«សម្រាប់កូននាគតូចរបស់បង!»

យូរណាស់ហើយ ដែលយើងមិនដែលមានពេលសូម្បីតែគិតផងថា តើយើងចេះសរសេរខ្មែរដែរអត់?

ចំណែកអក្សរនេះ វាជាអក្សររបស់យើង ឬមួយក៏មនុស្សប្រុសណាផ្សេង?

ហេតុអ្វីបានជាយើងស្រាប់តែចង់ដឹង?

ប្រុសស្អាតលើកហត្ថសន្សឹមៗ មកទាញយកប៊ិចពីហោប៉ៅអាវ។

ជាទូទៅ គេប្រើវាសម្រាប់ចុះហត្ថលេខាតែប៉ុណ្ណោះ។

ច្រើនឆ្នាំមកនេះ តួអក្សរតែមួយក៏គេមិនដែលបញ្ចេញដែរ។

មិនបានគិតច្រើនទេ.....ចិត្តគេអន្ទះសាជាងទឹកមុខដែលស្មើៗស្រគត់ស្រគំនោះ។ គេទាញក្រដាសដដែលមកសង្កត់លើតុឫស្សីហើយឈ្ងោកសរសេរ។

«នាងមែនទេ  មនុស្សស្រីពិតប្រាកដនៅក្នុងអតីតកាលរបស់ខ្ញុំ?»

គេសរសេរឃ្លាចេញមកវ៉ាវ ជាសំណួរដែលបេះដូងមួយនេះ ស្រេកឃ្លានចម្លើយយ៉ាងអន្ទះសា។

ចុងក្រោយគេនៅស្ងៀមភាំងចំពោះតួអក្សររបស់ខ្លួនឯង។

អ្វីម្យ៉ាងបុកទ្រូងនាយឱ្យក្តុកក្តួល ហើយគ្មានសកម្មភាពអ្វីបន្ថែមក្រៅតែពីឈរធ្មឹងផ្ទៀងតួអក្សរចាស់ថ្មីទាំងទ្វេ។

ពីក្រោយខ្នងនាយ អតីតប្រធាននិស្សិតដើរចូលមកជាមួយទឹកសុទ្ធពីរដប ដែលគេទើបតែចេញទៅយកពីក្នុងឡានមកទទួលភ្ញៀវពិសេសជំនួសប្អូនស្រីកម្សត់របស់គេ។

**ប្តូរជីវិត ស្វែងរកអតីតកាល**

វឌ្ឍនៈស្ទុះស្ទារត់កាត់ចំណោមមនុស្សមករកថៅហ្វាយកម្លោះ ដែលបានឃ្លាតឆ្ងាយជាយូរមកហើយ។ គេហក់ឱប Lorenzoកណ្តាលចំណោមអ្នកដំណើរហើយក៏លូកដៃទទួលយកសាក់កាដូពីថៅហ្វាយមកស្ពាយជំនួសតាមទម្លាប់ធ្វើឱ្យប្រុសស្អាតត្រូវស្រឡាំងកាំង។

«យូរណាស់ហើយ អ្នកប្រុសនៅដដែល!»

ទីនេះគឺបាងកក។ គេមិនបានឱ្យវឌ្ឍនៈមកភ្នំពេញទេ គឺគេឡើងមករកអតីតជំនួយការ បញ្ជាក់ថាគេជឿសម្តីវឌ្ឍនៈដែលឱ្យលាក់រឿងទាំងនេះពីគូដណ្តឹងនិងភ្នែកច្រមុះទាំងអស់របស់នាង។

«ខ្ញុំរីករាយណាស់ដែលជួបបងវិញ! តោះបង!»

គេកៀកកនាំយកបុរសនេះចាកចេញពីចំណតអាកាសយានឆ្ពោះទៅរកមន្ទីរពេទ្យតាមការគ្រោងទុក។

នៅលើជំនិះ វឌ្ឍនៈលបមើលមុខនាយ។ វង់ភក្រ្តដែលសល់តែមួយចំហៀង ក៏ល្មមបង្ហាញភាពស្រស់សង្ហាស្ងប់ស្ងាត់ហើយស្រពាប់ស្រពោន។ មនុស្សជំនិតកើតចិត្តសង្ស័យទ្វេឡើង។ នៅពេលជំនិះរត់ថយក្រោយ វឌ្ឍនៈរឹតតែអន្ទះសា។ គេចាប់ផ្តើមថ្លើមពាសមេឃហែកវ៉ាលីសថៅហ្វាយមើលខ្វាក ហើយសន្សឹមៗសំណុំឯកសារពេទ្យដែលគេអាន បានធ្វើឱ្យដៃគេញ័រ។

គេកាត់ចិត្តងាកមកសង្ហើញសួរបញ្ជាក់៖

«អ្នកប្រុសសម្រេចចិត្តច្បាស់ហើយ?!»

សំណួរនេះលាន់មកគ្មានចម្លើយតបទេ តែភាពស្ងៀមស្ងាត់របស់ Lorenzoគឺស្មើនឹង Yes។

វឌ្ឍនៈនៅស្ងៀមវិញទាំងភ្នែកនៅកញ្ជឹងក។

គេដឹងមុនពេលមកដល់ទីនេះ ដែលថៅហ្វាយម្នាក់កំពុងក្បែរខ្លួនបានប្រាប់គេថា ចង់មានមនុស្សស្គាល់ចិត្តម្នាក់មកកំដរការវះកាត់ តែតាមផ្លូវពីអាមេរិកមកបាងកក ជំនួយការនេះ មិនដែលដឹងថាលទ្ធផលរបស់ថៅហ្វាយ មានតែពីរប៉ុណ្ណោះគឺទទួលបានការចងចាំ មកវិញ ឬមួយទៀត លែងក្រោកមកវិញជារៀងរហូត។

ហានិភ័យនេះហើយ ដែលអ្នកផ្ទះគេទាំងអស់ ព្រមទាំងស្រីដែលគេស្រលាញ់ផង បានសម្រេចចិត្ត ថា ជ្រើសយកជីវិតគេ ជាជាងអតីតកាលរបស់គេ?

ហេតុអ្វីគេមកដឹងរឿងពិតនៅវិនាទីចុងក្រោយទៅវិញ។

គេស្គាល់ចរិតបុរសនេះ Lorenzoសម្រេចអ្វីហើយ មិនងាយដូរចិត្តតាមហេតុផលអ្នកផ្សេងឡើយ ព្រោះអភិជនតែងតែទូទាត់ បញ្ជាក់ទិន្នន័យសព្វយ៉ាងមុនពេលគេសម្រេចចិត្តអ្វីមួយឡើងម្ល៉ោះហើយ គេមិនងាយបកក្រោយពិចារណាឡើងវិញដាច់ខាត។

អ្នកទាំងពីរនៅស្ងប់ស្ងៀមក្នុងបរិយាកាសដ៏ធ្ងន់ពាប់ ដែលគ្មានពាក្យអ្វីនឹងនិយាយទាំងអស់។ រហូតដល់បាងកករត់ថយក្រោយបានយូរគ្រែល ទើបអតីតមនុស្សជំនិតសម្រេចចិត្តថាត្រូវតែតវ៉ា៖

«ខ្ញុំយល់ថា បើមិនចាំអតីតកាលសប្បាយចិត្តដែរ  មិនបាច់ទាររាមកវិញទេ! បើអ្នកប្រុសសង្ស័យ និស្ស័យស្នេហាចាស់នៅឯជើងភ្នំមួយនោះមែន អាចសុំអ្នកនាងពិនណាផ្តាច់ពាក្យហើយ ចាប់ផ្តើម Datingជាថ្មីជាមួយសន្យាក៏បាន!»

Lorenzoសម្លឹងទៅទេសភាពខាងក្រៅ គេមិននិយាយមិនស្តី តែវឌ្ឍនៈអាចស្ទង់ដឹងថា ពីនេះ រហូតដល់គ្រែពេទ្យគ្មានអ្នកណាកែប្រែការសម្រេចចិត្តរបស់បុរសម្នាក់នេះបានទៀតឡើយ។

តើសំបុត្រមួយនោះមែនទេ? ដែលធ្វើឱ្យគេត្រូវតែរកខ្លួនឯងពិតត្រឡប់មកវិញ?

«ខ្ញុំសូមអង្វរ ឱ្យអ្នកប្រុសគិតម្តងទៀត!»

គេនិយាយតិចៗ ធ្វើឱ្យបុរសអភិជនងើយក្បាលផ្អែកពូកហើយធ្មេចភ្នែកសន្សឹមៗ ។

 គេនិយាយស្រាលៗដោយមិនងាកមកឡើយ៖

« គេចាំខ្ញុំបាន៦ឆ្នាំ ខ្ញុំត្រូវសងរបស់ទាំងនេះឱ្យគេ! គេមិនស្រលាញ់មនុស្សថ្មីទេ គេស្រលាញ់ខ្ញុំកាលពីមុន! បើអ្វីទាំងអស់ដែលខ្ញុំដឹងមក គឺជាការពិត ខ្ញុំមិនស្តាយនឹងប្តូរជីវិត យកការពិតដ៏ល្អទាំងនោះត្រឡប់មកវិញទេបង!»

## អនុស្សាវរីយ៍ចុងក្រោយ

នៅពេលដែលជាតិថ្នាំសន្លប់សន្ធប់ពេញរាងកាយ សង្វាក់បេះដូងចុងក្រោយរបស់ Lorenzo  នឹកឃើញតែមនុស្សស្រីរោគចិត្តម្នាក់នោះ។

នាងមានរោគចិត្ត មនុស្សម្នាថានាងមិនល្អ ហេតុអ្វីបេះដូង ចង់ទទួលស្គាល់អូន ហើយចង់យកអូនទៅឆ្ងាយ ទៅកន្លែងដែលគ្មានអនាគតឬអតីតកាល ក៏ជាកន្លែងដែលមានតែយើងពីរនាក់?

គេបិទភ្នែកឈឹងហើយ ការគិតទាំងអស់បានបញ្ចប់។

ក្រុមវេជ្ជបណ្ឌិតកំពុងតតាំងច្បាំងយកឈ្នះភាពអកុសលដែលកំពុងតាមទាមទារចូលមកយាយីប្រាណបុរសខ្ពស់ស្រាវម្នាក់នេះ។ ត្បិតតែជាតិថ្នាំខ្លាំងបានធ្វើឱ្យគេលែងឈឺចាប់ លែងកើតទុក្ខព្រួយ ប៉ុន្តែមិនដឹងពេលវេលារំលងទៅយូរប៉ុណ្ណាទេ គេបាននឹកឃើញ.....

គឺ ព្រឹត្តិការណ៍ នៅក្រោយពិធីសប្បុរសធម៌ដ៏រំដើបរំជួលមួយនោះ.....

Lorenzoអើយ គ្រប់យ៉ាងដែលចូលជ្រៅក្នុងបេះដូងទៅហើយ វាពិបាករលុបបាត់ទៅវិញណាស់។បើឯងជាមកវិញមែន ឯងក៏គួរតែនឹកឃើញនូវរឿង សំខាន់មួយនេះឡើងមកវិញមុនគេអ៊ីចឹងដែរ។

ដូចពាក្យថា ពេលខ្លះបេះដូងមើលឃើញពីអ្វីដែលភ្នែកមើលមិនឃើញ។

ក្នុងការនឹកឃើញមុនគេបង្អស់ គឺ Lorenzo ម្នាក់កាលពី៥ឆ្នាំមុន បានត្រឡប់មកដល់ផ្ទះអនាគតក្នុងសម្លៀកបំពាក់សាមញ្ញ តែបេះដូងពេញទៅដោយកម្តៅស្នេហ៍ ។

បន្ទាប់ពីលានាងចេញទៅធ្វើការងារបន្ទាន់ឱ្យដំណឹងទៅភ្នំពេញឱ្យបរិវារមកទទួល យកខ្លួន គេនឹកដល់កូននាគតូចណាស់ បានចុងក្រោយនេះគេ សម្រេចចិត្តថា នឹងមិនអាចបកទៅអាមេរិកដោយមិនមាននាងទៅជាមួយឡើយ។

គេចូលមករកនាងវិញពេលព្រលប់មួយ។

ផ្ទះនេះនៅតែស្ងប់ស្ងាត់ដូចកាលពីគេទើបនឹងរត់លូនមកដល់ដំបូង។ ក្លិនឆៃថាវនិងគ្រៃឬស្សី ប៉ុន្តែគ្មាននាង???

គេចាប់ផ្តើមចេះភ័យ!

ចរិតគួរឱ្យស្រលាញ់របស់ស្រីតូចនេះមិនមែនជាការសម្តែងទេ ដូច្នេះអនុស្សាវរីយ៍ពិតវាពិបាកភ្លេចណាស់។ គេដឹងថាខ្លួនឯងស្រលាញ់នាងខ្លាំង ជាពិសេសពេលដែលចុះពីម៉ូតូឌុបមកហើយមិនបានឃើញនាងឈរហាលឆៃថាវក្បែរមាត់បង្អួចដូចការរំពឹងទុក។

គេចាប់ផ្តើមរំលឹករឿងគ្រប់យ៉ាងឡើងវិញទាំងអស់ច្បាស់ដូចថ្ងៃ.....

«ចាំខ្ញុំបង្រៀនបងឯងធ្វើឬកឱ្យសមជាអ្នកមាន!»

គេត្រូវនាងអូសទីណាត់ទីណែងឱ្យឈរកណ្ដាលផ្ទះបង្រៀនឱ្យដើរតួជាអ្នកមានដែលគ្រប់គ្នាដណ្ដើមចង់ Selfie ដាក់ Facebook។

«បងឯងមិនដែលពាក់អាវធំមិនដែល ចូលពិធីធំ ដើរឆ្គងអ៊ីចឹងហ្មង! នៀកៗចាំខ្ញុំធ្វើឱ្យមើល! Lorenzoគេដើរអ៊ីចេះ!» ប្រឹងរៀនឡើងត្រូវមានការងារច្រើនណាស់ត្រូវទៅ រកជួលអាវធំមកពាក់ទៀតណ៎ា! ហើយសក់នៀក សក់មើលទៅមិនសមអ្នកមានសោះត្រូវកាត់ចេញ!»

គេញញឹមទាំងរាងកាយដេកស្ងៀមក្រោមសំពត់ស។ គេញញឹមទាំងមិនខ្វល់ថាខ្លួនឯងងើបចេញពីគ្រែនេះបានឬអត់? គេញញឹមព្រោះតែវង់ភក្ត្រតូចនារី ស្រីដែលគេអាណិតស្រលាញ់ហើយចុះចាញ់ចិត្តដ៏ស្មោះត្រង់របស់នាង។

គេនៅជិតជាមជ្រាលជ្រៅក្នុងបេះដូងកម្សត់នេះ នូវកែវភ្នែកស្លុងភ្ញាក់ផ្អើលលាយស្រឡាំងកាំងរបស់នាង ដែលឃើញគេចេញមកពីក្នុងជួររថយន្តខ្មៅស្ទិលបន្តគ្នា៦គ្រឿង ហើយដើរចូលមកលើកម្រាលព្រំក្រហម ក្នុងចំណោមអ្នកហែហមដ៏ហ៊ឺកហ៊ាក់។

សន្យា របស់បង !

ពន្លឺភ្នែកភាំងៗរបស់អូនដែកឈ្លក់លង់នឹងស្នាមញញឹមស្រស់របស់ព្រានម្នាក់នេះ បានធ្វើឱ្យវា ត្រូវទន់ដៃ ទម្លាក់ដាវកាំបិត ឈប់ចង់ប្រហារបេះដូងមនុស្សស្រី ហើយចង់ចំណាយជីវិតដែលនៅសល់ជាមួយកូននាគរបស់បងតែម្នាក់គត់ប៉ុណ្ណោះ។

គេវែកវង់គេចចេញពីក្រុមអ្នកស្រុកដែលដណ្ដើមគ្នាមកសំពះនិងរលាក់ដៃសុំថតរូប ហើយគោលដៅគេគឺរកមើលកូននាគដែលស្លៀកពាក់សុភាពរាបសាគួរឱ្យស្រលាញ់វិញ។

ឃើញភ្នែកភ្លឺចិញ្ចាចរបស់នាងកាលណា គេចាប់បញ្ចេញដំណើរសង្ហា ដូចរាជសី ដែលត្រៀមតែនឹងបានថ្លៃ មកស្ម័គ្រមេត្រីមិនឱ្យរបូតទៅណាបាន .....

គេចាំជានិច្ច កែវភ្នែកនាងដែលសម្លឹងនាយស្រទន់ជំនួសឱ្យភាសាបេះដូងដែលថា លង់គេជ្រៅហើយ គឺលង់ដល់ភាំងតែម្ដង។

ពន្លឺភ្នែកនាង និងស្នាមញញឹមតិចៗ របស់នាង ពិតបណ្ដោយគេឱ្យមានអារម្មណ៍ថាខ្លួនឯងសង្ហាជាងរាជបុត្រក្នុងរឿងបុរាណ ដែលធ្វើឱ្យនាងសឹងភ្លេចដកដង្ហើមបានពេលគេចូលទៅកាន់តែកៀក។

កម្តៅបេះដូងគេលោតឡើងជាលំដាប់ នៅពេលដែលគេយល់ថា ដង្ហើមនាងក៏នៅកៀកគ្នា កៀកសែនកៀក ស្និទ្ធិសែនស្និទ្ធ ។

ប្រមាណជាពីរចំអាមពីនាង ស្រីក្មេងនេះ ទម្លាក់ភ្នែកនាងចុះ មកទើរត្រឹមតែដើមទ្រូងគេ លែងហ៊ានសម្លឹងមុខគេ ព្រោះចាញ់កម្ពស់ឬចាញ់ចិត្តគេ ចាញ់ស្នាមញញឹមព្រានរបស់ផងក៏មិនដឹង?

តាមថា កូននាគ អាចនឹង ងើបមុខឡើងមើលគេមិនរួច ព្រោះកំពុងអៀនមហាអៀន។

ស្រីតូច បានចាញ់ប្រាបភាពជាបុរសនិងមន្តស្នេហ៍របស់គេរហូតលែងរវល់នឹង កាមេរ៉ាទាំងឡាយដែលកំពុងឆ្មក់ត្របាញ់មក។

ក្រៅពីនិយាយបង្វែងតើនាងចេះស្អីទៀតទៅ?

«មនុស្សបងឯង ប្រាប់ឱ្យធ្វើអ៊ីចេះទៅធ្វើអ៊ីចុះ! ឱ្យជួលអាវធំពាក់ បងឯងជួលឡានមកម្តង៦គ្រឿង! ខ្ញុំបានស្អីទៅបង់គេ? ហើយអស់ប៉ុន្មានជួលប៉ុណ្ណឹង? ខ្ញុំបានលុយឯណាឱ្យថ្លៃឡានគេនៀក»

នាងងើបមុខមកជាមួយកង្វល់ តែនាងត្រូវទើរព្រោះគេសម្លឹងនាងយ៉ាងស្រទន់។ សន្យានៅគាំងកណ្តាលសមុទ្រស្នេហាដែលល្ងឹងល្ងើយដូចគ្មានអ្នកណានៅទីនេះក្រៅតែពីនាងហើយនឹងគេ។ សូរសព្ទមេក្រូលាន់មកកោកៗផ្តាច់សង្វាក់ដង្ហើមក្តៅឧណ្ហៗរបស់នាង។

«ហើយបងឯងបានលុយពីណាមក?ខ្ចីគេក៏មិនគួរខ្ចីយកមុខម្លឹងៗដែរ!ងាប់ហើយ ខ្ញុំបានអីសងគេ? »

ដៃគេលូកមករកកដៃនាង ។

កណ្តាប់ដៃគេត្រជាក់ ស្រាលតែមិនអាចរើរួចឡើយបុរសនេះមិនឆ្លើយនឹងសំណួរនាង គេបែរជា អូសនាំនាងចាកចេញចោលកម្មវិធី។

នាងភាំងៗ តែក៏បណ្តោយជើងឱ្យចាកចេញទៅតាមគេ រហូតដល់ត្រូវគេរុញចូលក្នុងឡានទៀតក៏នៅតែភាំង។

នាងនិងគេស្និទ្ធស្នាលណាស់ សម្តីអីក៏ធ្លាប់និយាយចប្រែចតដាក់គេគ្មានខ្លាចក្រែងចិត្តបន្តិចណានោះដែរ ប៉ុន្តែពេលនេះហេតុអីហារមួយម៉ាត់មិនរួចសោះ?

គេជាន់ហ្គាដាក់ល្បឿនរស្រើបលើផ្លូវជាតិ ធ្វើឱ្យនាងងាកមករកសម្លឹងនាយថ្លៃរ ។

គេក្របួចមាត់ញញឹមហើយងាកមកប៉ះកែវភ្នែកជាមួយនាង។

គេស្អាតយ៉ាងនេះ នាងនិយាយអីរួច បើថ្ពាល់ក៏ក្រហម ហើយបេះដូងកំពុងច្រាលសង្កត់រាងកាយរារាំងអណ្ដាត ហើយក៏គ្របសន្ធប់មកលើបញ្ញានាងអស់រលីងទៀត។

បានអីទប់ទល់ទៅសន្យាអើយ?

គេញញឹមអស់ចិត្តក៏ងាកមកមើលទិសដៅខាងមុន។

«ស្អាតណាស់ មនុស្សស្អាត!»

គេរអ៊ូតិចៗ ធ្វើឱ្យនាងដែលទើបតែងាកចេញទៅសម្លឹងរកសម្គាល់ផ្លូវបែរជាងាកមកវិញខ្វាកព្រោះភ្ញាក់ពាក្យសរសើរប្លែកៗចេញពីមាត់នរៈអភិជន។

«ថាខ្ញុំហ្នែន? សរសើរខ្ញុំ?»

ស្រីតូចចង្អុលមុខខ្លួនឯង ធ្វើឱ្យគេដៀងកន្ទុយភ្នែកមកទាំងគ្រីតភ្ញាញ់។

គេសួរវិញភ្លាមតែប្រើសំឡេងស្រាលៗ បបោសអង្អែលត្រចៀកអ្នកនៅក្បែរ៖

«មានមនុស្សប៉ុន្មាននាក់ក្នុងឡានហ្នឹង? !»

នាងញញឹមផង រក្សាភាពមាំស្មើវិញម្ដងៗផង ព្រោះមិនអាចបញ្ឆោទឹកមុខបាន។

«ហើយបងបើកឡានគេទៅណា?!»

នាងសួរធ្វើឱ្យគេងើយមុខយ៉ាងមានអំនួត ហើយនិយាយធ្វើហី៖

«ឡានអ្នកណាគេ? »

នាងជ្រួញចិញ្ចើមតបផ្ទួង៖

«ខ្ញុំម៉េចដឹង ?បងឯងអ្នកទៅជួលគេមកឡើងហ៊ីហា ហើយមិនដឹងឡានរបស់ពីណាគេទេ?!»

ប្រុសស្អាតធ្វើមុខឌឺដងតែមិនងាកមក។ គេនៅស្ងៀមដំអក់ពេលនាងកំពុងរង់ចាំសម្ដីគេបញ្ជាក់ន័យគេក៏រឹតតែមិនហារនិយាយអ្វីទៀតសោះ ធ្វើឲ្យស្រីតូចធុញបូញមាត់រអ៊ូ៖

«គេឱ្យធ្វើអ៊ីចេះទៅធ្វើអ៊ីចុះ? គេឱ្យមកជួយរើសសាររោងទៅហ៊ីហាយកឡានគេមកជិះប្រណាំងលេង! ....គេឱ្យកាត់សក់ទៅជា....»

បុរសបន្ថយល្បឿនស៊ីញ៉ូអែបតាំងពីពេលណានាងមិនដឹងទេ។ នាងដឹងខ្លួនគឺពេលឡានគេឈប់ទៅហើយ។ គេដាក់ហត្ថាខាងឆ្វេងមកលើចង្កូតហើយឯប្រាណនៅសល់បែរមកសម្លក់នាង ។

ភ្នែកមនុស្សប្រុសម្នាក់នេះ ដូចម្រឹគឃើញចំណី គេសម្លក់យើងធ្វើអី? ហេតុអីគេឈប់ឡាន?

មេឃនៅព្រឹកនៅឡើយ។ អាកាសខាងក្រៅថ្ងៃមិនទាន់ច្បាស់ប៉ុន្មានផងព្រោះនេះជាដងព្រៃ ពុះព្រៃកដោយដងផ្លូវស្ងាត់យូរៗម្តងទើបមានជំនិះបោលកាត់មួយ។

នាងលែងមាត់រអ៊ូលែងងរង៉ក់ ហើយចាប់ផ្តើមលូកដៃរាវរកចេញពីឡាន ។

ដៃឆ្វេងគេលូកមកចាប់កដៃមួយនោះ មិនឱ្យប៉ះគន្លឹះសោបាន ។ រាងកាយគេក៏កំពុងលោមកពាំងពីមុខខ្លួនប្រាណតូចល្អិតរបស់នាងដូចគ្នា។

ក្លិនអ្នកទីក្រុង ដែលជាក្លិនដំបូងបង្អស់នាថ្ងៃនាងត្រកងប្រាណគេដែលរងរបួស បានកើតមានឡើងមកប៉ះនាសាម្ចាស់ផ្ទះអនាគតសាជាថ្មី។

ភាពសិចស៊ីនៃបុរសនេះ ធ្វើឱ្យស្រីក្មេងទៅជាភាំងៗសម្លឹងមុខនាយ។

«ឈប់និយាយច្រើន! ឈប់បញ្ហាច្រើន! ឈប់រអ៊ូច្រើន! ឈប់ធ្វើដូចឯងហ្នឹងអ្នកចេះ គ្មានអ្នកណាចេះដល់ទៀត! ឮ?»

នាងតបវិញភ្លាមទាំងភ្នែកខ្លួននៅកំដរព្រិចៗ មិនរបេះចេញពីរង្វង់ភ្នែកនាយមួយវិនាទីណាឡើយ៖

«ថាឱ្យអ្នកណា?!»

ដូចនាងគិតគឺគេមិនឆ្លើយ បែរជាឱនបបូរមាត់មក។

វាមិនខុសពីកុនបរទេសដែលធ្លាប់ធ្វើឱ្យអារម្មណ៍ស្រីស្អាតរំជើបរំជួលនោះទេ។ ដោយស្វ័យប្រវត្តិនាងលើកដៃទាំងទ្វេទៅតវ៉ាវាយវាត់លើនាយហើយក្បាលក៏ថយគេចចេញទៀត។

Lorenzoប្រហែលជាគិតមិនដល់ទេដែលស្មានៗថា នារីស្អាតខ្ញីម្នាក់នេះ ដូចមនុស្សស្រីផ្សេងដែលគេធ្លាប់ជួប។

នាងមិនមានត្រង់ណាមើលទៅឱ្យសមថាកំពុងត្រៀមខ្លួននឹងទទួលយកស្នាមថើបដំបូងរបស់សង្សារសោះ។

គេចាប់ដៃនាងទាំងពីរជាប់ក្នុងប្រអប់ដៃស្តាំតែមួយ។ នាងរើកម្រើកដៃមិនរួច ហើយកែងដៃនាយគឺសង្កត់រាងកាយនាងនៅនឹងកៅអី។

ភ្នែកនាយគឺបំពានមកលើខ្សែភ្នែកនាង តាមរបៀបដូចស្តេចតោកំពុងសំញែងឫទ្ធមកកាន់សត្វតូចល្អិតដែលត្រៀមតែនឹងស្លាប់ក្នុងនាមជាចំណី។

នាងរើមិនបាន រេខ្លួនមិនកើត ណាមួយគ្រើតនឹងភ្នែកប្រុសម្នាក់នេះ ចិត្តមួយក៏រំជួលព្រោះស្នេហាគ្រាដំបូង ចិត្តមួយមិនទាន់ទទួលយកភាពស្និទ្ធស្នាលរវាងប្រុសនិងស្រីបាន នាងទៅជានិយាយមិនចេញបានត្រឹមង៉ុលៗ៖

«យ៉ាប់ម៉េះ លែងភ្លាម!»

«អត់លែង!»

«ឱ្យលែង!»នាងរំអួយនាយរឹតតែញញឹមហើយថែមកម្លាំងសួរបញ្ឈឺ៖

«លែងធ្វើអី?»

«លែងគេ!»នាងតបគ្មានន័យខ្លឹមសារអ្វី គឺពឹតតែតប តែនិយាយមិនបានវែងមិនបានត្រូវចុងដើមអីទាំងអស់ធ្វើទ្រូងបុរសរឹតតែនឹកក្នាញ់។

«ជិតរៀបការមានប្តីហើយ!ឈប់ធ្វើហួរសម្បោរ លេងទឹកភ្នែក ចាយសម្តីមាយា ឮនៅ?!»

«ពីណាមាយាដាក់បងឯង ពីណាយំចាយទឹកភ្នែកទៅ? មនុស្សយ៉ាប់ មួយយប់សោះចេញចរិតយ៉ាប់! ប្រយ័ត្នគេស្អប់ឈប់មើលមុខឈប់និយាយរក!ប្រាប់ឱ្យដឹង»

គេហួសចិត្តខ្លាំងតែញញឹមតិចៗប៉ុណ្ណោះ។ បុរសនេះធម្មតាមិនចេះនិយាយច្រើនអ្វី ទាំងអស់ ស្រាប់តែមកត្រូវស្នេហ៍នារីដ៏ Cuteនេះ លោតែមិនអាចទប់សម្តី ចេះផ្ចាញ់នាង ឱ្យហួររ៉ាវដូចទឹកបាន៖

«ដឹងស្អី? ឈប់និយាយរកបានប៉ុន្មាននាទី? មនុស្សមាត់អត់គម្របចច្រែត គេចនិយាយរួចដែរ?»

នាងរើខ្លាំងៗព្រោះខឹងដែលថ្ពាល់នាយនៅក្បែរ ស្លាំងព្រោះអំណាចចិត្តស្រលាញ់មួយទំហឹងកូនប្រុស តែមាត់ថាឱ្យនាងមិនដាក់ទឹក។ នាងកាន់តែរើ គេកាន់តែមាំ ហើយចុងក្រោយគេឱនមករកនាង តម្រង់សរសៃសក់ខ្មៅរលាស់រលោងព្រោះនាងឱនគេច។

ស្នាមថើបដំបូងនៃព្រាននារីដែលមិនចេះអាល័យមនុស្សស្រី ទីបំផុត មិនមែនថ្ពាល់ មិនមែនមាត់ ក៏មិនមែនទ្រូងនាងដែលពើងមកបង្អួតបេះដូងនាយ ។

គេថើបសក់នាងស្រាលៗ ហើយគេចាប់នាងជាប់យ៉ាងនេះ នាងគេចទៅណាគេនៅតែជម្នះថើបកេសាស្រីបានដដែលគឺថើបអស់ចិត្តអស់ចង់តែម្តង ទម្រាំគេព្រមឈប់ ហើយលែងកដៃនាងសន្សឹមៗ។

អ្វីមួយក្តៅៗស្រក់តក់ៗមកលើកំភួនដៃប្រុសស្អាត។

គឺទឹកភ្នែកស្រីស្អាតដែលកំពុងបង្កើនសម្រស់បេះដូងនាយឱ្យមានន័យហួសអ្វីនឹងថ្លែងបាន។

«ថាយំ យំមែន!!»

នាយនិយាយតិចៗ នាងប្រកែកមកវិញញ៉ាញ៖

«អ្នកណាយំ? គេមិនបានខ្លាចគេមិនបានភ័យ!»

«ចុះនេះស្អី?»

នាយចង្អុលទឹកភ្នែកលើផែនថ្ពាល់ ធ្វើឱ្យស្រីគ្រវាសម្រាមចេញដោយមានៈ ចំណែកបុរសនៅតែដាក់ម្រាមត្រឡប់មកវិញដដែល។

នាងប្រកែកប្រណាំងយ៉ាងណា គេនៅតែចចេស ទីបំផុតគេខ្ជិលរវល់ច្រើនក៏ទាញរាងកាយតូចល្អិតមកក្នុងលង្វែកទ្រូង។

ជាលើកដំបូងដែលនាងដឹងថា ការដែលត្រូវបានអ្នកណាម្នាក់ឱបផ្ទប់ជាប់នឹងដើមទ្រូងស្តាប់ចង្វាក់បេះដូងរបស់គេតើ មានអារម្មណ៍បែបណា?

កូននាគលែងទៅណា ក៏លែងរើបម្រះ។

កាលដែលនាងគ្រាគេ និងកាលដែលគេឱបចង្កេះនាងលើម៉ូតូ នៅតែមិនដូចរង្វង់ដៃនាពេលនេះឡើយ។

នារីសួរខ្លួនឯង៖

«គេជាសង្សារឯងហើយ មែនទេនាងសន្យាអើយ?»

«ស្រលាញ់បងបែបនេះរហូតឮអត់?!»

គេនិយាយមកខ្សឹបៗ នាងនៅគាំងជ្រកក្នុងដើមទ្រូងកក់ក្តៅសន្ធំដោយភ្លើងស្នេហ៍។

យើងស្រលាញ់គេក៏គេដឹង? នាងសួរខ្លួនឯងទាំងបេះដូងស្លន់ស្លោ។

«ទោះមានរឿងអីកើតឡើងក៏ដោយកុំចោលបងឱ្យសោះ!»

ចិត្តនាងស្រងេះស្រងោចនឹងពាក្យដែលថា «មានរឿងអីកើតឡើងក៏ដោយ».....

គេសម្លឹងភ្នែកនាង ហើយមិនចង់ឃ្លាតគ្នាទៅទាំងអញ្ចឹងឡើយ ប៉ុន្តែម្រាមដៃគេកម្រើក......វាជាពេលដែលគេត្រូវដឹងខ្លួនពីការសន្លប់មកវិញហើយ...ភាគនិទានស្នេហ៍នៅក្នុងការចងចាំដែលបានReloadមកវិញបន្តិចម្តងៗ ក៏បានដាច់សង្វាក់....

«Loren? អ្នកប្រុសLoren?»

វឌ្ឍនៈ ហៅតិចៗក្បែរត្រចៀកអ្នកជំងឺ......

«គាត់ដឹងខ្លួនហើយ!»

ជំនួយការម្នាក់នេះស្រែកហៅអ្នកផងទាំងអំណរ បន្ទាប់ពីចៅហ្វាយកំលោះដេកបែបនេះជិត៥២ម៉ោង......

ទំនាក់ទំនងជាវសៀវភៅនេះ ០១៥២១៣១១១